ព្រះរាជាណាចក្រកម្ពុជា

Rina

តុលាការកំពូល

ជាតិ សាសនា ព្រះមហាក្សត្រ

សភាផ្នែកព្រហ្មទណ្ឌ

*******

---

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥០

ចុះថ្ងៃទី០៤ខែធ្នូឆ្នាំ១៩៩៨

សាលដីកា

លេខ : ១៧

ចុះថ្ងៃទី២៨ខែកក្កដាឆ្នាំ១៩៩៩

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៩

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ឌិត | មុន្ទី | ប្រធាន |
| ២- | លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣- | លោក | សោម | សិរីវឌ្ឍ | ចៅក្រម |
| ៤- | លោក | ប្រាក់ | គឹមសាន | ចៅក្រមរបាយការណ៍ |
| ៥- | លោក | យស់ | សុខឿន | ចៅក្រម |

ក្រឡាបញ្ជីលោក សាន សុផាន

តំណាងមហាអយ្យការ លោក ហ៊ែន សារ៉ុន ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៥០ ចុះថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់តុលាការកំពូល ។

ពីបទ : ភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់

ពីបទ : ភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់ ពាក់សំលៀកបំពាក់ខុសបទបញ្ជា ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧ ខែសីហា ឆ្នាំ១៩៩៥ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រាទី ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម មាត្រាទី ៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រាទី១ ច្បាប់ស្តីពីការផ្តន្ទាទោសកាន់កាប់ និង ពាក់សំលៀកបំពាក់ឯកសណ្ឋានខុសបទបញ្ជា ។

១- ជនជាប់ចោទឈ្មោះផ្លូង រ៉ុឌ្ធី ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ៣៣ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ របររកស៊ី កងទ័ពកងឯកភាពរថក្រោះ ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ ៣៣៣ ក្រុមទី៦ ផ្ទះលេខ ១៦៣ សង្កាត់ទួលទំពូងII ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ផ្លូង សំអាត ( ស ) ម្តាយឈ្មោះ ខូច ណៃ ប្រពន្ធឈ្មោះ មី ឈឿយា មានកូន០១នាក់

ក្នុងឃុំ ។

មានមេធាវី លោក ទូត លុច ។

២- ជនជាប់ចោទឈ្មោះវ៉ាន់ យ៉ឿន ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនៅឃុំក្រាំង-ស្វាយ ស្រុកព្រះស្តេច ខេត្តព្រៃវែង របររកស៊ី មេបញ្ជាការកងរាជអាវុធហត្ថប្រចាំស្រុកមានជ័យ ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ ២០$E_1$ ក្រុមទី១២ ផ្លូវលេខ ១៣៩ សង្កាត់វាលវង់ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ ញូង សុវណ្ណ ( ស ) ម្តាយឈ្មោះ ម៉ែន សាក់ ( រ ) នៅលីវ ។ ក្នុងឃុំ ។

៣- ជនជាប់ចោទឈ្មោះ ថៅ ចំណាន ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ របររកស៊ី រត់ម៉ូតូឌុប ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ ១៨៣ ក្រុមទី១១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះ ថៅ សម្បត្តិ ( ស ) ម្តាយឈ្មោះ អ៊ុង សារ៉ា ( រ ) ទោសពីមុន មានធ្លាប់ជាប់គុក ១ឆ្នាំ ( ព្រៃស ) ។ ក្នុងឃុំ ។

៤- ជនជាប់ចោទឈ្មោះឈុន ទី ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម របររកស៊ីឈ្នួកជេរម៉ូតូ ទីលំនៅមុនថ្ងៃចាប់ខ្លួន ផ្ទះសង់ថ្មីទល់មុខមហោស្រពទន្លេបាសាក់ ក្រុងភ្នំពេញ ឪពុកឈ្មោះនឹង យិន ( រ ) ម្តាយឈ្មោះ សៅ យ៉ែន ( រ ) ប្រពន្ធឈ្មោះតាវ ណារី មានកូន ១នាក់ ។ ទោសពីមុន មានធ្លាប់ជាប់គុក ១០ខែ ( PJ ) ។ ក្នុងឃុំ ។

៥- ជនជាប់ចោទឈ្មោះ សេង សម្បត្តិ ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកអូរាំងឪ ខេត្តកំពង់ចាម របររកស៊ី អង្គរក្សឱ្យថៅកែក្រុមហ៊ុនណាហ្គា ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ ៥៣៩ ក្រុមទី៦ ផ្លូវអាចារ្យមៀន សង្កាត់បឹងកេងកង ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ ឃី ប៊ុនសេង(រ) ម្តាយឈ្មោះ ពិន ស្រៀវ ប្រពន្ធឈ្មោះ សៀន ពិសី មានកូន ១នាក់ ។ ក្នុងឃុំ ។

៦- ជនជាប់ចោទឈ្មោះឈឿង នាង ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រៃឃុំ ខេត្តព្រៃវែង របររកស៊ីជួសជុលម៉ូតូ ទីលំនៅមុនថ្ងៃចាប់ខ្លួននៅមុខសាលាខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ ឈឿង ម៉ូវ ( ស ) ម្តាយឈ្មោះ គង់ នៅ ( រ ) ប្រពន្ធឈ្មោះហួត វណ្ណា មានកូន ១នាក់ ។ ទោសពីមុន មានធ្លាប់ជាប់គុក ។ ក្នុងឃុំ ។

៧- ជនជាប់ចោទឈ្មោះគីម សំអាត ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទប្រុសអាយុ៣០ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកពញាឮ ខេត្តកណ្តាល របររកស៊ីលក់ចំបល្លុក ទីលំនៅមុនថ្ងៃចាប់ខ្លួន ក្រុមទី១២ ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្តាល ឪពុកឈ្មោះ គីម អន ( រ ) ម្តាយឈ្មោះ ពយ ឃឹម(រ) ប្រពន្ធឈ្មោះ ហម សុភិន មានកូន ៤នាក់ ។ ក្នុងឃុំ ។

មានមេធាវីលោក ទូត លុច

៨- ជនជាប់ចោទឈ្មោះ មៀវ មុន្នី ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកសៀក ស្រុកពារាំង ខេត្តព្រៃវែង របររកស៊ីគ្មាន ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ៨៩ ក្រុមទី៤១ ផ្លូវព្រះសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ មៀវ សាមិត ( រ ) ម្តាយឈ្មោះ

ឈុន សឿរ ( រ ) នៅលើរ ។ ក្នុងឃុំ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ៃឃន ចាន់ធេន ( ជាទុងបណ្តឹងសាទុក្ខ ) ភេទប្រុស ជាតិខ្មែរ សញ្ជាតិអាមេរិកកាំង របររកស៊ី អនុប្រធានសន្តិសុខប្រចាំក្រុមហ៊ុនណាហ្គា ។

មេធាវី គ្មាន

- តាមបណ្តឹងសាទុក្ខលេខ៣៤ ចុះថ្ងៃទី ២៤_៨_៩៨ របស់ឈ្មោះ ដួង វុទ្ធី និង បណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី៣១_៨_៩៨ របស់ឈ្មោះ គីម សំអាត ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមរបាយការណ៍លេខ ៧០៧/៩៥ ចុះថ្ងៃទី ២៣_៨_៩៥ របស់ស្នងការនគរបាលក្រុងភ្នំពេញ ស្តីពីអំពើភេរវកម្មចាប់បុគ្គលិកកាស៊ីណូណាហ្គា ជំរិតយកប្រាក់ កាលពីថ្ងៃទី ១៧_៨_៩៥ វេលាម៉ោង ៣ និង៣៥នាទី ចំនួន ៣នាក់ ដោយជនល្មើសទូរស័ព្ទគំរាមទារប្រាក់ ១០ម៉ឺនដុល្លា ពីជនរងគ្រោះ ក្រោយពីបានទទួលលុយមុន ៥ម៉ឺនដុល្លាមក ជនល្មើសបានដោះលែងជនរងគ្រោះ២នាក់សិន គឺឈ្មោះយៀម ធៀបហរ និង សេង សម្បត្តិ ហើយនៅសល់ម្នាក់ទៀតឈ្មោះ លឹម គីមហុក ត្រូវក្រសួងមានសមត្ថកិច្ចធ្វើការរំដោះខ្លួនបាន ហើយចាប់ខ្លួនជនល្មើសបាន ១១នាក់ គឺឈ្មោះវ៉ាន់ ហ៊ឿន , គីម សំអាត , ឈុន ទី , ថៅ_ចំណាន , សេង សម្បត្តិ , សៀង នាង , ប៉ែន ចុល , មាស ចំនួនសុផល , សេង សុធា , ឈុន ភក្តី និង ឈុន រធា ព្រមទាំងដកហូតវត្ថុតាងអាវុធAK ២ដើម M16 ១ដើម K59 ចំនួន ១ដើម M79 ចំនួន១ដើម រថយន្តម៉ាកក្សូឡា ១គ្រឿង ជារបស់ជនរងគ្រោះ ។

- តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ៃឃន ចាន់ធេន ឆ្លើយថា ខ្លួនជាអ្នកតំណាងឱ្យជនរងគ្រោះ តាមរយៈលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ១៧_១២_៩៥ ឱ្យចូលមកដោះស្រាយករណីចាប់លោក លឹម គីមហុក និង ហូ ឃី ខ្លួនសំណូមពរឱ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ និង ប្តឹងទាមទារប្រាក់ខាតបង់ ៥ម៉ឺនដុល្លា ជម្ងឺចិត្ត ១៥ម៉ឺនដុល្លា សរុប ២០ម៉ឺនដុល្លា ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាង អយ្យការ អម តុលាការក្រុងភ្នំពេញ ថា :

១_ ឈ្មោះ គីម សំអាត , មៀរ មុន្នី ពីបទភេរវកម្ម និងប្រើប្រាស់អាវុធខុសច្បាប់ពាក់សំលៀកបំពាក់ឯកសណ្ឋានខុសបទបញ្ជា តាមបញ្ញត្តិមាត្រាទី ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម , មាត្រាទី៥៤ ច្បាប់ព្រហ្មទណ្ឌ និង មាត្រាទី១ ច្បាប់ស្តីពីការផ្តន្ទាទោស កាន់កាប់អាវុធ និងពាក់សំលៀកបំពាក់ខុសបទបញ្ជា នៅក្រុងភ្នំពេញ ។

២_ ឈ្មោះ ដួង វុទ្ធី , វ៉ាន់ ហ៊ឿន , ឈុន ទី , ថៅ ចំណាន , សេង សម្បត្តិ សៀង នាង , ឈុន ពង្សពិសិដ្ឋ ពីបទ អំពើភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់ នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_៩៥ បទល្មើសដែលមានចែង និង ផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ២ ច្បាប់ស្តីពី អំពើភេរវកម្ម និង មាត្រា៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣_ រំលត់បណ្ដឹងអាជ្ញាលើឈ្មោះ ទេម ផា និង ឈ្មោះ ឈុន ពីកា ។

៤_ លើកលែងទោសប្រកាន់ឈ្មោះ អ៊ុក សឿង

៥_ បង្អង់បណ្ដឹងអាជ្ញាលើឈ្មោះ អុន ព្រោះគ្មានសាវ័តាជាតិ ។

៦_ បញ្ជូនសំណុំរឿងទៅតុលាការដើម្បីជំនុំជំរះ ។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣១ " ក " ចុះថ្ងៃទី ១១ ខែមិនា ឆ្នាំ១៩៨៦ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច ៖

១_ ផ្ដន្ទាទោសដាក់ពន្ធនាគារឈ្មោះ ជួង វុទ្ធី ចំនួន១៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី ១០ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ ។

- ផ្ដន្ទាទោសដាក់ពន្ធនាគារឈ្មោះវ៉ាន់ ប៊ុន ចំនួន១៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី ២៤_៨_១៩៨៥។
- ផ្ដន្ទាទោសដាក់ពន្ធនាគារឈ្មោះ ថោ ចំណាន , ឈុន ទី ចំនួន ១៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ទី ២៤_៨_១៩៨៥ ។

ពីបទ : ប្រព្រឹត្តអំពើភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់នៅក្រុងភ្នំពេញ កាលពីថ្ងៃទី១៧_៨_៨៥ តាមមាត្រា២ ច្បាប់ស្ដីពីការផ្ដន្ទាទោសអំពើភេរវកម្ម និង មាត្រា ៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២_ ផ្ដន្ទាទោសដាក់ពន្ធនាគារឈ្មោះគីម សំអាត ចំនួន១៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី២៤_៨_១៩៨៥ ពីបទអំពើភេរវកម្មប្រើប្រាស់អាវុធខុសច្បាប់ និងពាក់សំលៀកបំពាក់ខុសបទបញ្ញា តាមមាត្រា ២ ច្បាប់ស្ដីពីអំពើភេរវកម្ម មាត្រា ៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា ១ ច្បាប់ស្ដីពីការកាន់កាប់អាវុធ និង ពាក់សំលៀកបំពាក់ខុសបទបញ្ញា ។

៣_ ផ្ដន្ទាទោសឈ្មោះឈុន ពង្សពិសិដ្ឋ ចំនួន១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ពីបទ សមគំនិតប្រព្រឹត្តអំពើភេរវកម្ម និងប្រើប្រាស់អាវុធខុសច្បាប់នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_១៩៨៥ តាមមាត្រា ២ ច្បាប់ស្ដីពីអំពើភេរវកម្ម និង មាត្រា ៦៤_៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤_ ផ្ដន្ទាទោសឈ្មោះសឿង ឆាង ចំនួន១ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី ២៤_៨_៨៥ ពីបទភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់នៅក្នុងក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_៨៥ ។

៥_ ផ្ដន្ទាទោសឈ្មោះ មៀវ មុន្នី ចំនួន ២ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី២_១_១៩៨៦ តែទោសនេះ ត្រូវព្យួរទាំងអស់ ដោយទុករយៈពេលសាកល្បង ៥ឆ្នាំ ពីបទ : ភេរវកម្មប្រើប្រាស់អាវុធខុសច្បាប់និងពាក់សំលៀកបំពាក់ខុសបទបញ្ញានៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_១៩៨៥ ។

៦_ ផ្ដន្ទាទោសឈ្មោះ សេង សម្បត្តិ ចំនួន៧ខែ គិតពីថ្ងៃឃុំខ្លួនទី ២៤_៨_៨៥ តែទោសនេះត្រូវព្យួរទាំងអស់ ដោយទុករយៈពេលសាកល្បង ៥ឆ្នាំ ពីបទប្រើប្រាស់អាវុធគ្មានច្បាប់អនុញ្ញាតនៅភ្នំពេញ កាលពីថ្ងៃទី ១៧_៨_៨៥ តាមមាត្រាទី៥៤ និង ៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ សំរេចឱ្យរួចមុខលើឈ្មោះ សេង សម្បត្តិ ពីបទ ភេរវកម្ម ។

៧_ បង្គាប់ឱ្យជួង វុទ្ធី , វ៉ាន់ ហ៊ើន , ឈុន ទី ហៅ ឃុត ប៊ុនលី , ថោ ចំណាន ពីម សំអាត , ម៉ៀវ មុន្នី , សៀង នាង , ឈុន ពង្សពិសិដ្ឋ រួមគ្នាសងសោហ៊ុយបង់ខាត និង ជម្ងឺចិត្ត ៨ម៉ឺនដុល្លា ទៅដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

វត្ថុតាងមានក្នុងកំណត់ហេតុចុះថ្ងៃទី ២៣_៨_៩៥ របស់អយ្យការ អមតុលាការក្រុងភ្នំពេញ សំរេចរឹបអូសជាសម្បត្តិរដ្ឋ ។

៨_ សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខជនជាប់ចោទនិងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះឈុន ពង្សពិសិដ្ឋ សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែ តាមច្បាប់កំណត់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ២៦ របស់ឈ្មោះ ជួង វុទ្ធី , បណ្តឹងឧទ្ធរណ៍លេខ ២៧ របស់ឈ្មោះវ៉ាន់ ហ៊ើន , បណ្តឹងឧទ្ធរណ៍លេខ ២៨ របស់ឈ្មោះថោ ចំណាន , បណ្តឹងឧទ្ធរណ៍លេខ២៩ របស់ឈ្មោះ ឈុន ទី និង ឈ្មោះ ពីម សំអាត ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣០ ចុះថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៩៦ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា : សូមរក្សាសាលក្រមរបស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៦១ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ១៩៩៨ ដែលបានសំរេច ៖

១_ ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨_៣_១៩៩៦ របស់ជនជាប់ចោទឈ្មោះ ជួង វុទ្ធី វ៉ាន់ ហ៊ើន , ពីម សំអាត , ថោ ចំណាន , និងឈុន ទី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់តែលើកចោលដោយខុសនឹងគតិច្បាប់ ។

២_ តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣១ ( ក ) ចុះថ្ងៃទី១១_៣_៩៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ប៉ុន្តែកែប្រែចំណុចទី១ និង ទី២ ជាថ្មីវិញ ។

៣_ ក_/ផ្តន្ទាទោសឈ្មោះជួង វុទ្ធី ដាក់ពន្ធនាគារកំណត់១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី១០_១១_៩៥ ពីបទ ភេរវកម្ម និង កាន់កាប់អាវុធខុសច្បាប់ នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_១៩៩៥ ។ តាមបញ្ញត្តិមាត្រា ២ ច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម និង មាត្រា ៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ខ_/ផ្តន្ទាទោសឈ្មោះពីម សំអាត ដាក់ពន្ធនាគារកំណត់១០ឆ្នាំគិតពីថ្ងៃឃុំខ្លួនទី២៤_៨_៩៥ ពីបទ : ភេរវកម្មកាន់កាប់អាវុធខុសច្បាប់ និង ពាក់សំលៀកបំពាក់ខុសឋានៈបញ្ញានៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_១៩៩៥ ។ តាមបញ្ញត្តិមាត្រា២ ច្បាប់ស្តីពីអំពើភេរវកម្មមាត្រា៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា១ ច្បាប់ស្តីពីការផ្តន្ទាទោសកាន់កាប់អាវុធខុសច្បាប់ និងពាក់សំលៀកបំពាក់ឯកសណ្ឋានខុសឋានៈបញ្ញា។

គ/ផ្តន្ទាទោសឈ្មោះឈុន ទី ហៅ ឃុត ប៊ុនលី និងឈ្មោះថោ ចំណាន ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី ២៤_៨_៩៥ ពីបទភេរវកម្ម និង ប្រើប្រាស់អាវុធខុសច្បាប់នៅក្រុងភ្នំពេញ

កាលពីថ្ងៃទី ១៧_៨_៩៥ ។ តាមបញ្ញត្តិមាត្រា ២ ច្បាប់ស្តីពីអំពើភេរវកម្ម និង មាត្រា ៥៥_៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

ឃ_/ផ្តន្ទាទោសឈ្មោះរ៉ាន់ ហ៊ើន ដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនទី២៤_៨_៩៥ ពីបទ :អំពើភេរវកម្ម និងប្រើប្រាស់អាវុធខុសច្បាប់ នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៧_៨_៩៥ តាមបញ្ញត្តិមាត្រា២ ច្បាប់ស្តីអំពីអំពើភេរវកម្ម និង មាត្រា ៥៥_៦៨ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤_ សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ជួង វុទ្ធី ,គីម សំអាត , រ៉ាន់ ហ៊ើន , ឈុន ទី , ថោ ចំណាន ចំពោះមុខមេធាវីការពារជនជាប់ចោទឈ្មោះទូច លុច , ធង់ សុភក្តិ , សំ សំណាង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

- បានឃើញបណ្តឹងសាទុក្ខលេខ៣៤ ចុះថ្ងៃទី២៤_៨_៩៨ របស់ឈ្មោះជួង វុទ្ធី និង ប្តឹងសាទុក្ខតាមបណ្តឹងលេខ៣៨ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៨ របស់ឈ្មោះគីម សំអាត ដែលបានប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ១៥_០១_៩៩ របស់ឈ្មោះ ជួង វុទ្ធី " ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណា ចុះថ្ងៃទី ១៥_០១_៩៩ របស់ឈ្មោះ គីម សំអាត " ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញលិខិតបង្គាប់ឱ្យធ្វើសារណាឆ្លើយតប ចុះថ្ងៃទី០២ខែមិនាឆ្នាំ១៩៩៩របស់តុលាការកំពូល បង្គាប់ឱ្យឈ្មោះម៉ៃឃន ខាត់ឆេន ជាចុងបណ្តឹងសាទុក្ខ ធ្វើសារណាឆ្លើយតបដោះសារពីសារណារបស់ឈ្មោះជួង វុទ្ធី និងគីម សំអាត ហើយដែលឈ្មោះនេះបានទទួលនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ រួចហើយប៉ុន្តែមិនបានធ្វើសារណាឆ្លើយតបជូនមកតុលាការកំពូលវិញទេ ជាហេតុធ្វើឱ្យគ្មានសារណាឆ្លើយតប របស់ចុងបណ្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានស្តាប់អំណានសាវតាជាតិដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ម៉ៃឃន ខាត់ឆេន " ជាចុងបណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា :

១_ បណ្តឹងសាទុក្ខរបស់ឈ្មោះ ជួង វុទ្ធី និង គីម សំអាត ស្ថិតក្នុងកំណត់ច្បាប់គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

២_ ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១៦១ ចុះថ្ងៃទី ១៧_៧_៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ ជួង វុទ្ធី "ជាម្ចាស់បណ្តឹងសាទុក្ខ"

នៅពេលជំនុំជំរះថា : តុលាការថ្នាក់ក្រោមសំរេចពុំត្រឹមត្រូវ ព្រោះនៅថ្ងៃកើតហេតុ ខ្ញុំបាទនៅផ្ទះខ្វល់ទំពួង ពេញ១ថ្ងៃល្ងាច នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៥ ខ្ញុំបាទនិងឈ្មោះគីម សំអាត នាំគ្នាទៅទិញឡាននៅខេត្តកំពង់ស្ពឺ នៅវេលាម៉ោង៣រសៀល បន្ទាប់ពីខ្ញុំបាទ និង គីម សំអាត យកកូនត្រីមកចិញ្ចឹមនៅតាខ្មៅវិញមក។

ខ្ញុំបាទពុំបានប្រព្រឹត្តបទល្មើសទេ ចម្លើយនៅនគរបាល នគរបាលពុំបានសួរចម្លើយខ្ញុំបាទឡើយ នគរបាលបង្ខំឱ្យខ្ញុំបាទផ្តិតមេដៃលើក្រដាសស ៣៩សន្លឹក គ្រប់ចម្លើយខ្ញុំបាទយ៉ាងណានោះ ខ្ញុំបាទសូមបដិសេធចោល ។

- បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះគីម សំអាត " ជាម្ចាស់បណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះថា: តុលាការថ្នាក់ក្រោមកាត់ក្តីអយុត្តិធម៌ ព្រោះខ្ញុំពុំបានប្រព្រឹត្តបទល្មើសទេ នៅថ្ងៃកើតហេតុ ខ្ញុំនៅផ្ទះមើលប្រពន្ធឆ្លងទន្លេ លុះថ្ងៃទី ១៨_៨_១៩៩៥ ខ្ញុំទៅទិញឡានជាមួយ ជួង រ៉ូនី នៅខេត្តកំពង់ស្ពឺ ប៉ុន្តែទិញពុំបាន ដោយពុំជួបម្ចាស់ឡាន លុះព្រឹកឡើងថ្ងៃទី១៩_៨_១៩៩៥ ខ្ញុំបាទទៅផ្ទះម្ចាស់ឡានសួររកទិញឡានម្តងទៀត តែត្រូវប៉ូលីសចាប់ខ្លួនខ្ញុំតែម្តង ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ទូត លុច ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះជួង រ៉ូនី " ជាម្ចាស់បណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះថា : សាលាឧទ្ធរណ៍សំរេចដាក់គុកជួង រ៉ូនី ចំនួន ១០ឆ្នាំ និងរួមគ្នាសងចំនួន ៨ម៉ឺនដុល្លាទៅដើមបណ្តឹងរដ្ឋប្បវេណី ឃើញថា ពុំត្រឹមត្រូវព្រោះថា ៖

១_ ភស្តុតាង ជួង រ៉ូនី ពុំបានប្រើទូរស័ព្ទ០១៧ ប្រព្រឹត្តបទល្មើសទេ តាមការឆ្លើយបញ្ជាក់ពីប្រធានក្រុមហ៊ុនទូរស័ព្ទ មកប្រធានតុលាការក្រុងភ្នំពេញ ។

២_ សាក្សី : មានសាក្សីឆ្លើយផ្ទុយគ្នាឈ្មោះ ប៉ែន ថុល ឆ្លើយថាពុំស្គាល់ឬឃើញជួង រ៉ូនី នៅផ្ទះខ្លួនឯខេត្តកំពង់ស្ពឺនោះទេ ។ សាក្សីឆ្លើយដាក់បន្ទុក ជួង រ៉ូនី ដើម្បីសុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យជាក់ស្តែងតុលាការបន្ធូរបន្ថយទោសឱ្យពួកគេមែន ។ ដូច្នេះសូមតុលាការដោះលែងជួង រ៉ូនី ដោយក្តីអនុគ្រោះ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ទូត លុច ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះគីម សំអាត " ជាម្ចាស់បណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះថា : គីម សំអាត គ្រាន់ជាអ្នកទិញឡានតាមរយៈ ជួង រ៉ូនី ប៉ុណ្ណោះ ហើយសមត្ថកិច្ចធ្វើការចាប់ខ្លួន គីម សំអាត ក្នុងសំណុំរឿងចំពាក់ស៊ីវិល តុលាការមិនត្រូវចោទប្រកាន់ គីម សំអាត ពីបទ : ពាក់សំណុំរឿងចំពាក់ខុសបញ្ហានោះទេ ហើយមានសាក្សីជាប្រជាជនរស់នៅក្នុងភូមិជាមួយគីម សំអាត ជាច្រើនបានឆ្លើយបញ្ជាក់ថា នាថ្ងៃកើតហេតុគីម សំអាត នៅក្នុងភូមិជាមួយខ្លួន ។ ដូច្នេះសូមតុលាការដោះលែង គីម សំអាត ម្នាក់ទៀត ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : សូមរក្សាទុកសេចក្តីសន្និដ្ឋាននៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ សេចក្តីសន្និដ្ឋានការពារ

របស់មេធាវីជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ២៩_៨_៩៨ របស់ឈ្មោះជួង វុទ្ធី និងបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ៣១_៨_៩៨ របស់ឈ្មោះ ធីម សំអាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៩ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា បទល្មើសដែលកើតឡើងកាលពីថ្ងៃទី ១៧_៨_៩៥ នៅក្រុងភ្នំពេញពុំមែនជាបទល្មើសជាក់ស្តែងទេ ប៉ុន្តែការចាប់ខ្លួនជនជាប់ចោទឈ្មោះធីម សំអាត បែរជាពុំមានដីកាពីអាជ្ញាធរតុលាការ ហើយឃុំខ្លួនជនជាប់ចោទលើសពេលវេលាដែលច្បាប់បានកំណត់ទើបបញ្ជូនខ្លួន ជនជាប់ចោទទៅអយ្យការ អមតុលាការក្រុងភ្នំពេញ ដែលជាការរំលោភទៅនឹងមាត្រា ១០ ,១៣ និង និង ១៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា ៣៩ ,៤៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ក្នុងការសួរចម្លើយជនជាប់ចោទឈ្មោះធីម សំអាត ទាំងប្រាំមួយលើកមាន តែការសួរចម្លើយមួយលើក ប៉ុណ្ណោះនៅមុខចៅក្រមស៊ើបសួរ មានវត្តមានមេធាវី ដូច្នេះការសួរចម្លើយជនជាប់ចោទពីបទឧក្រិដ្ឋដែលគ្មានវត្តមានមេធាវីនោះ គឺជាការរំលោភទៅនឹងមាត្រា១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ហើយភស្តុតាងដែលបានមកពីការសួរចម្លើយបែបនេះ ពុំអាចទទួលយកជាការបានឡើយ ។

- យល់ឃើញថា គ្រប់ចម្លើយរបស់ជនជាប់ចោទ ទាំងអស់ ដែលធ្វើឡើងត្រឹមត្រូវតាមច្បាប់ ពុំមានចម្លើយណាមួយបញ្ជាក់ថា ជនជាប់ចោទឈ្មោះធីម សំអាត បានចូលរួមប្រព្រឹត្តបទល្មើស កាលពីថ្ងៃទី ១៧_៨_៩៥ នៅក្រុងភ្នំពេញឡើយ ម្យ៉ាងទៀតនៅចំពោះមុខតុលាការ និង សាលាឧទ្ធរណ៍ជនជាប់ចោទឈ្មោះ ធីម សំអាត បានឆ្លើយថានៅយប់ថ្ងៃកើតហេតុ ខ្លួននៅផ្ទះមានប្រជាជនពេញភូមិដឹងឮ ត្រង់ចំណុចនេះ តុលាការពុំទាន់ធ្វើការស៊ើបអង្កេតនៅឡើយ ។

- យល់ឃើញថា ក្នុងការសួរចម្លើយជនជាប់ចោទឈ្មោះ ជួង វុទ្ធី ទាំងបីលើកមានតែការសួរចម្លើយ មួយលើកប៉ុណ្ណោះនៅមុខចៅក្រមស៊ើបសួរ មានវត្តមានមេធាវី ដូច្នេះការសួរចម្លើយជនជាប់ចោទពីបទឧក្រិដ្ឋ ដែលគ្មានវត្តមានមេធាវីនោះគឺ ជាការរំលោភទៅនឹងមាត្រា១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា៧៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ហើយភស្តុតាងដែលបានមកពីការសួរចម្លើយបែបនេះ ពុំអាចទទួលយកជាការបានឡើយ ។

- យល់ឃើញថា ចម្លើយរបស់ជនជាប់ចោទ ដាក់បន្ទុកទៅលើឈ្មោះ ជួង វុទ្ធី ពុំទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយ ត្បិតមានជនជាប់ចោទមួយចំនួនបានឆ្លើយថាខ្លួនពុំបានឃើញវត្តមានឈ្មោះជួង វុទ្ធី

នៅពេលប្រព្រឹត្តបទល្មើសនោះទេ ដូច្នេះគប្បីធ្វើការស៊ើបអង្កេតបន្ថែមទៀត ។

- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលដីកាដោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះ រឿងនេះកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាប្រព្រឹត្តទណ្ឌលេខ១៦១ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ.

១_ ទទួលបណ្តឹងសាទុក្ខលេខ៣៩ ចុះថ្ងៃទី ២៩_៨_៩៨ របស់ឈ្មោះផ្លុង វុទ្ធី និង បណ្តឹងសាទុក្ខលេខ៣៨ ចុះថ្ងៃទី ៣១_៨_៩៨ របស់ឈ្មោះតឹម សំអាត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីកាប្រព្រឹត្តទណ្ឌលេខ១៦១ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៥០ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៩ ។